# វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពគ្រូបង្គោល ស្តីពី
# "ការអភិវឌ្ឍន៍គំនិតថ្មី និងបច្ចេកវិទ្យាថ្មីដោយមានការចូលរួម"

វគ្គបណ្តុះបណ្តាលនេះ ត្រូវបានប្រព្រឹត្តិទៅនៅមន្ទីរកសិកម្មខេត្តកំពង់ចាម នៅថ្ងៃទី ១៥-១៧ ខែ កក្កដា ឆ្នាំ ២០០៨ ដែលមានអ្នកចូលរួមសរុប ៣២ នាក់ ស្ត្រី ៧ នាក់ ក្នុងនោះមានស្ថាប័នចំនួន ២២ ចូលរួមគឺមន្ទីរកសិកម្មចំនួន ៩ (តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង ព្រៃវែង ស្វាយរៀង បាត់ដំបង កំពង់ធំ ពោធិ៍សាត់ កំពង់ចាម) ។ មន្ទីរអភិវឌ្ឍន៍ចនួន ១ នាយកដ្ឋានចំនួន ២ (នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម) អង្គការមិនមែនរដ្ឋាភិបាលចំនួន ៧ (សេដាក ចំរើនជាតិខ្មែរ ស្រែខ្មែរ NAPA, NAS, FDAO, FIDAC)។ ស្ថាប័នអប់រំចំនួន ៣ (សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មកំពង់ចាម សាលាជាតិកសិកម្មព្រែកលៀប) និងក្រុមប្រឹក្សាឃុំធ្លក ខេត្តតាកែវ ។

គោលបំណងសំខាន់សម្រាប់វគ្គបណ្តុះបណ្តាលនេះគឺ:




- បង្ហាញពីដំណើរការ និងវិធីសាស្ត្រនៃការធ្វើការជាមួយកសិករពិសោធន៍
- ជំនាញសម្របសម្រួលក្នុងការធ្វើការជាមួយកសិករ
- វិធីសាស្ត្រនៃការរុករកគំនិតថ្មីក្នុងមូលដ្ឋាន ។

ជាលទ្ធផលយើងសង្កេតឃើញថា

- អ្នកដែលបានចូលរួមនៅក្នុងវគ្គបណ្តុះ-បណ្តាលនេះ បានធ្វើការឆ្លុះបញ្ចាំងឡើងវិញនូវអ្វីដែលបានរៀន និងអនុវត្តកន្លងមកនៅតាមស្ថាប័នរបស់ខ្លួននិមួយៗ ដែលធ្វើឱ្យពួកគាត់មើលឃើញច្បាស់ពីចំណុចខ្វះខាតដែលត្រូវកែលម្អ និងពង្រឹងបន្ថែមនូវចំណុចដែលធ្វើបានល្អកន្លងមក
- ក្រៅពីនេះ អ្នកចូលរួមបានមើលឃើញ និងយល់កាន់តែច្បាស់បន្ថែមទៀតពីបទពិសោធន៍ ក៏ដូចជាគំនិតថ្មីរបស់កសិករដែលធ្វើបានតាមរយៈការចុះទស្សនកិច្ចសិក្សា
-ម្យ៉ាងវិញទៀត ពួកគាត់ក៏បានទទួលចំណេះដឹងបន្ថែមទៀត ទាក់ទងនឹងដំណើរការ និងវិធីសាស្ត្រនៃការធ្វើការជាមួយកសិករពិសោធន៍ជំនាញក្នុងការសម្របសម្រួលសម្រាប់ការធ្វើការជាមួយកសិករ ព្រមទាំងវិធីសាស្ត្រក្នុងការរុករកគំនិតថ្មីក្នុងមូលដ្ឋានរបៀបនៃការកត់ត្រាព័ត៌មានដែលពួកគាត់ធ្វើបាន ក្រោយពីទទួលបានការបណ្តុះបណ្តាល និងការពង្រឹងសមត្ថភាពរបស់ប្រូលីណូវ៉ាកម្ពុជា ។